**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣៣៣❀៣៣៣

**សាលាដំបូងខេត្តកែប**

-សំណុំរឿងព្រហ្មទណ្ឌលេខៈ ២៥

ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២២

-សាលក្រមលេខៈ ១៨ (គ)

ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០២២

# តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកែប

បានបើកសវនាការជំនុំជម្រះជាអសាធារណៈ នៅថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០២២

និងប្រកាសសាលក្រម នៅថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០២២

## ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក ជាចៅក្រមប្រឹក្សា

លោក ជាចៅក្រមប្រឹក្សា

## តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកែប

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកែប

## ដើម្បីជំនុំជម្រះលើជនជាប់ចោទឈ្មោះ

១. [redacted] **ស៊ីថាច** ភេទប្រុស អាយុ ៣៧ឆ្នាំ ជនជាតិខ្មែរ មុខរបរ កម្មករសំណង់ ទីកន្លែងកំណើត និងទីលំនៅមុនពេលឃុំខ្លួន ភូមិ [redacted] ខេត្តតាកែវ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ យ៉ាន (រ) ប្រពន្ធឈ្មោះ [redacted] សុផាត មានកូន ០២ នាក់ ជានីតិជន ទោសពីមុន ធ្លាប់ជាប់ពន្ធនាគាររយៈពេល០១ឆ្នាំពីបទហិង្សាដោយចេតនា។

-ឃុំខ្លួន នៅថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០២២ ។

២. [redacted] **តុលា** ភេទប្រុស អាយុ ១៦ឆ្នាំ ៣ខែ ជនជាតិខ្មែរ មុខរបរ កម្មករចំការម្រេច ទីកន្លែងកំណើត និងទីលំនៅមុនពេលឃុំខ្លួន ភូមិ [redacted] ខេត្តកំពត ឪពុកឈ្មោះ [redacted] ឈុន (រ) ម្តាយឈ្មោះ [redacted] ហ័រ នៅលីវ, ទោសពីមុន គ្មាន ។

-ឃុំខ្លួន នៅថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០២២ ។

-មេធាវីការពារជនជាប់ចោទ **លោកមេធាវី** [redacted]

៣. [redacted] **សុភ័ក្រ** ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិខ្មែរ មុខរបរ បើកឡានដឹកដី ទីកន្លែងកំណើត និងទីលំនៅមុនពេលឃុំខ្លួន ភូមិ [redacted] ខេត្តកែប ឪពុកឈ្មោះ [redacted] សុខហេង (រ) ម្តាយឈ្មោះ [redacted] សុខុម (រ) ប្រពន្ធឈ្មោះ [redacted] ជីណា ,ទោសពីមុន គ្មាន ។

-ឃុំខ្លួន នៅថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០២២ ។

-មេធាវីការពារជនជាប់ចោទ **លោកមេធាវី** [redacted]

ជាប់ចោទពីបទ**ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្ទះជួលស្ថិតនៅក្នុងភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៤. [redacted]**វ៉ាន់ចាន់សីហា ហៅ ខូច** ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន នៅភូមិ[redacted] ខេត្តកែប ឪពុកឈ្មោះ [redacted]សុខុម (ស) ម្តាយឈ្មោះ [redacted]វ៉ាន់ច័ន្ទដារ៉ា (ស) ទោសពីមុន ធ្លាប់ជាប់ពន្ធនាគារខេត្តកំពតពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ។

-ឃុំខ្លួន នៅថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០២២ ។

ជាប់ចោទពីបទ**ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្ទះជួលស្ថិតនៅក្នុងភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## <u>អំពីអង្គហេតុ</u>

កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង ១៤ និង ៤០ នាទី កម្លាំងការិយាល័យប្រឆាំងគ្រឿងញៀននៃកងរាជអាវុធហត្ថខេត្តកែប បានចុះបង្ក្រាបករណីជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្ទះជួលស្ថិតនៅក្នុងភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប ដោយបានឃាត់ខ្លួនឈ្មោះ ១/.[redacted] ស៊ីថាច ភេទប្រុស អាយុ ៣៧ឆ្នាំ , ២/.[redacted]តុលា ភេទប្រុស អាយុ ១៧ឆ្នាំ , ៣/.[redacted]សុភ័ក្រ ភេទប្រុស អាយុ ៣៦ឆ្នាំ។ ក្រោយមកសមត្ថកិច្ចបានចាប់ខ្លួនឈ្មោះ [redacted]វ៉ាន់ចាន់សីហា តាមដីកាបង្គាប់អោយចាប់ខ្លួន។ ឈ្មោះ [redacted]ស៊ីថាច និង [redacted]វ៉ាន់ចាន់សីហា ជាអ្នកជួញដូរថ្នាំញៀន។ ចំណែកឈ្មោះ [redacted]សុភ័ក្រ និង [redacted] តុលា បានទិញថ្នាំញៀនពីឈ្មោះ [redacted] ស៊ីថាច និង [redacted] វ៉ាន់ចាន់សីហា ហៅ ខូច ដើម្បីយកមកប្រើប្រាស់។

## ចម្លើយករណីដែលបានលើកឡើងនាពេលសាកសួរ

-ជនជាប់ចោទឈ្មោះ [redacted] **ស៊ីថាច** បានឆ្លើយថា ខ្លួនរៀនបានថ្នាក់ទី២ មានកូន២នាក់ក្នុងបន្ទុក កូនតូចមានអាយុ៧ឆ្នាំ។ ខ្លួនសារភាពថាបានប្រព្រឹត្តដូចការចោទប្រកាន់មែន។ កាលពីថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង ៦ ព្រឹក ឈ្មោះ រត់ ភេទប្រុស អាយុប្រហែលជាង ៣០ឆ្នាំ រស់នៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប បានជិះម៉ូតូមកផ្ទះជួលរបស់ខ្លួននៅក្នុងភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប ខណៈពេលដែលខ្លួនកំពុងធ្វើម៉ូតូរបស់ខ្លួន គេក៏មកសួរទិញថ្នាំញៀនចំនួនដប់ម៉ឺនរៀលពីខ្លួន ហើយខ្លួនបានឆ្លើយថាមិនមានថ្នាំញៀនទេ។ បន្ទាប់មកគេក៏ជិះម៉ូតូត្រឡប់ទៅវិញ លុះដល់ម៉ោង ១០ និង ៣០នាទីព្រឹក ថ្ងៃខែឆ្នាំដដែល ឈ្មោះ រត់ក៏បានជិះម៉ូតូមកផ្ទះខ្លួនម្តងទៀត ដោយមកសុំទិញថ្នាំញៀនដដែល ។ ពេលនោះខ្លួនមិនមានថ្នាំញៀននោះទេ ហើយខ្លួនក៏បានទូរស័ព្ទទៅឈ្មោះ ស្វិត ភេទប្រុស អាយុប្រហែល ៣៥ឆ្នាំ នៅបែកគួស ដើម្បីទិញថ្នាំញៀនពីវាក្នុងតម្លៃ ដប់ម៉ឺនរៀល ហើយវាក៏យល់ព្រមលក់ថ្នាំញៀនឱ្យមកខ្លួន ។ ខ្លួនបានលុយពីឈ្មោះ រត់ ផ្ញើតាមវីង ឱ្យទៅឈ្មោះ ស្វិត ។ ប្រហែល ៣០ នាទីក្រោយមក ឈ្មោះ ស្វិត ក៏បានផ្ញើថ្នាំញៀនតាមឡានតាក់ស៊ីមកឱ្យខ្លួន ហើយខ្លួនក៏បានឡើងទៅយកថ្នាំញៀននោះនៅកំពង់ត្រាច ចំនួន ០១ កញ្ចប់ ។ ពេលទទួលបានថ្នាំញៀនហើយ ខ្លួនក៏បានប្រគល់ថ្នាំញៀនឱ្យទៅឈ្មោះ រត់ ហើយឈ្មោះ រត់ បានវែកថ្នាំញៀននោះបានជា ០២ កញ្ចប់ ដោយវាទុកនៅនឹងខ្លួនវាចំនួន ០១ កញ្ចប់ និង ០១ កញ្ចប់ទៀត វាបានយកទៅលក់ឱ្យគេបន្តទៀត ។ បន្ទាប់មកឈ្មោះ រត់ ក៏បានចាកចេញពីផ្ទះខ្លួន បានមួយសន្ទុះក្រោយមក ក៏មានសមត្ថកិច្ចចូលមកឃាត់ខ្លួន និងឆែកឆេរលើរូបខ្លួន ឃើញមានថ្នាំញៀនចំនួន ០៨ កញ្ចប់ ពិតមែន ។ ខ្លួនចាប់ផ្តើមលក់ថ្នាំញៀនក្នុងអំឡុងឆ្នាំ ២០២១ គឺនៅពេលដែលខ្លួនបានចេញពីពន្ធនាគារ ហើយមកធ្វើជាកម្មករសំណង់នៅខេត្តកែប ក៏បានជួបឈ្មោះ [redacted] តុលា ហើយខ្លួនក៏បានសួរទៅឈ្មោះ [redacted] តុលា ដើម្បីរកទិញថ្នាំញៀន ដោយគេប្រាប់ថា ឈ្មោះ [redacted]វ៉ាន់ចាន់សីហា ហៅ ខូច ភេទប្រុស អាយុប្រហែលជាង ២០ ឆ្នាំ គឺមានលក់ រួចខ្លួនក៏បានទាក់ទងទៅឈ្មោះ ខូច ដើម្បីសុំទិញថ្នាំញៀន ពីវាក្នុងតម្លៃ ដប់ម៉ឺន រៀល ។ ខ្លួនទិញថ្នាំញៀនពីឈ្មោះ ខូច ចំនួន ០៥ ដង មកហើយ ហើយឈ្មោះ ខូច ក៏បានបបួល

ខ្លួនឱ្យទៅនៅជាមួយវា ។ ខ្លួនក៏បានរស់នៅជាមួយ ឈ្មោះ ខូច បានរយៈពេល ០៤ ខែ ដោយក្នុងអំឡុងពេលនោះ ខ្លួនជាអ្នកលក់ថ្នាំញៀនឱ្យឈ្មោះ ខូច ព្រោះឈ្មោះ ខូច បានប្រាប់ឱ្យខ្លួននៅអង្គុយមុខផ្ទះ ដើម្បីចាំមុំយ មកយកថ្នាំញៀន។ ដោយរាល់ថ្ងៃគឺតែងតែមានអ្នកមកទិញថ្នាំញៀនពីខ្លួនមិនចេះដាច់ ដោយអ្នកខ្លះទិញក្នុងតម្លៃចាប់ពី ៣០០០០(បីម៉ឺន) រៀល ទៅ ៤០០០០ (បួនម៉ឺន) រៀល បន្ទាប់មកខ្លួនក៏មានជម្លោះជាមួយឈ្មោះ ខូច ហើយក៏ប្រឡប់ទៅខេត្តតាកែវ វិញ ។ នៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ ២០២២ ខ្លួនក៏បានត្រឡប់ទៅខេត្តកែបវិញ ក្នុងគោលបំណងមកធ្វើបន្ទប់ទឹកឱ្យគេម្នាក់ ហើយខ្លួនក៏បានទាក់ទងទៅឈ្មោះ ម៉ាប់ ភេទប្រុស អាយុ ២០ឆ្នាំ ដែលរស់នៅជាមួយឈ្មោះ ខូច ដើម្បីសុំទិញថ្នាំញៀនពីវាក្នុងតម្លៃ ១០០០០០ (ដប់ម៉ឺន) រៀល ហើយពេលនោះ ខ្លួនក៏បានស្គាល់ឈ្មោះ [redacted]សុភ័ក្រ ភេទប្រុស តាមរយៈឈ្មោះ ម៉ាប់ ក្រោយមកឈ្មោះ[redacted]សុភ័ក្រ បានទាក់ទងមកខ្លួនដើម្បីសុំទិញថ្នាំញៀន ក្នុងតម្លៃ ២០០០០ (ពីរម៉ឺន) រៀល ទៅ ៣០០០០ (បីម៉ឺន) រៀល ហើយខ្លួនក៏បានលក់ឱ្យគេចំនួន ០៣ ដង ។ ខ្លួនបានដឹងថា ថ្នាំញៀនដែល មាំ សុភ័ក្រ បានទិញពីខ្លួន គឺយកទៅប្រើប្រាស់ម្តង២០០០០(ពីរម៉ឺន)រៀល។ ចំណែក ឈ្មោះ [redacted] តុលា គឺខ្លួនបានស្គាល់គេតាំងពីពេលដែលខ្លួនមករស់នៅផ្ទះរបស់ឈ្មោះ ខូច មកម្ល៉េះ។ ខ្លួនសូមបញ្ជាក់ថា មុនដំបូងគឺសមត្ថកិច្ចឃាត់ខ្លួនតែម្នាក់ឯងនោះទេ ហើយខ្លួនក៏ប្រាប់សមត្ថកិច្ចថាខ្លួនបានទិញថ្នាំញៀនពីឈ្មោះ [redacted] តុលា ពេលនោះសមត្ថកិច្ចក៏បានឱ្យខ្លួនទាក់ទងទៅឈ្មោះ [redacted] តុលា ដើម្បីទិញថ្នាំញៀនក្នុងតម្លៃ ៦០០០០ (ប្រាំមួយម៉ឺន) រៀល។ ឈ្មោះ [redacted] តុលា ក៏បានយកថ្នាំញៀនមកឱ្យនៅផ្ទះរបស់ខ្លួន ក៏ត្រូវសមត្ថកិច្ចចាប់ខ្លួនតែម្តង ។ សមត្ថកិច្ចបានឃាត់រូបខ្លួនហើយបានធ្វើតេសពិនិត្យទឹកនោមលើរូបខ្លួន ជាលទ្ធផលគឺវិជ្ជមាន។ ចម្លើយដែល ខ្លួនបានឆ្លើយទាំងនៅចំពោះមុខសមត្ថកិច្ច នៅដំណាក់កាលអយ្យការ និង ដំណាក់កាលចៅក្រមស៊ើបសួរ គឺសុទ្ធតែជាពាក្យពិត ពុំមានការបង្ខិតបង្ខំឡើយ។

-ជនជាប់ចោទឈ្មោះ [redacted] **តុលា** បានឆ្លើយថា ខ្លួនមានអាយុ១៧ឆ្នាំ រៀនបានថ្នាក់ទី៧ មានឪពុកអាយុ ៧៧ ឆ្នាំពិការជើង។ កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោងប្រហែល ៣ រសៀល ខណៈពេលដែលខ្លួនកំពុងនៅផ្ទះស្រាប់តែឈ្មោះ កែវ ស៊ីថាច បានទូរស័ព្ទមកខ្លួនដើម្បីទិញថ្នាំញៀនក្នុងតម្លៃ ៦០០០០ (ប្រាំមួយ) ម៉ឺនរៀល បន្ទាប់មកខ្លួនក៏បានជិះម៉ូតូទៅជួបឈ្មោះ ម៉ាប់ នៅចំណុចផ្ទះរបស់ឈ្មោះ អៀង វ៉ាន់ចាន់សីហា ហៅ ខូច ដែលត្រូវជាមេរបស់ឈ្មោះ ម៉ាប់ ពេលនោះខ្លួនបានប្រគល់ប្រាក់ចំនួន ៣០០០០ (បីម៉ឺន) រៀល ឱ្យទៅឈ្មោះ ម៉ាប់ ដោយនៅជំពាក់គេចំនួន ៣០០០០ (បីម៉ឺន) រៀល ទៀត ។ ឈ្មោះ ម៉ាប់ បានប្រគល់ថ្នាំញៀនឱ្យមកខ្លួនចំនួន ០១ កញ្ចប់ ហើយខ្លួនក៏យកថ្នាំញៀននោះមកលក់ឱ្យឈ្មោះ[redacted]ស៊ីថាច នៅចំណុចផ្ទះរបស់គេក្នុងតម្លៃ ៦០០០០ (ប្រាំមួយម៉ឺន) រៀល ប៉ុន្តែពេលមកដល់នៅចំណុចផ្ទះរបស់ឈ្មោះ [redacted] ស៊ីថាច ក៏ត្រូវបានសមត្ថកិច្ចចាប់ខ្លួន ហើយដកហូតបានថ្នាំញៀនចំនួន ០១ កញ្ចប់ពិតមែន ។ សមត្ថកិច្ចចាប់ខ្លួនបានដកហូតថ្នាំញៀនចំនួន ០១ កញ្ចប់តូច ម៉ូតូ ០១ គ្រឿង មិនស្គាល់ម៉ាកមានពណ៌ខ្មៅ លាយក្រហម ពាក់ស្លាកលេខ ភ្នំពេញ 1A-7570 និងទូរស័ព្ទ ០១ គ្រឿង ម៉ាក វីវ៉ូ ពណ៌ខ្មៅ ។ សមត្ថកិច្ចបានឃាត់រូបខ្លួន ហើយបានធ្វើតេសពិនិត្យទឹកនោមលើរូបខ្លួន ជាលទ្ធផលគឺវិជ្ជមាន។ ខ្លួនគ្រាន់តែទិញថ្នាំញៀនតាមដែលឈ្មោះ [redacted] ស៊ីថាច ប្រើប៉ុណ្ណោះ មិនបានយកចំណេញអ្វីទេ ព្រោះគិតថាឈ្មោះ[redacted]ស៊ីថាច អោយខ្លួនប្រើប្រាស់ដែរ។

-ជនជាប់ចោទឈ្មោះ[redacted] **សុភ័ក្រ** បានឆ្លើយថា ខ្លួនរៀនបានថ្នាក់ទី៦ មានកូន ២នាក់ក្នុងបន្ទុក កូនតូចអាយុ ៨ឆ្នាំ។ ខ្លួនទទួលស្គាល់ថាបានប្រើប្រាស់ថ្នាំញៀនប្រាកដមែន តែមិនដែលលក់ដូរថ្នាំញៀននោះទេ។ កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោងប្រហែល ៨ ព្រឹក ខ្លួនបានជូនកូនខ្លួនទៅរៀន បន្ទាប់មកក៏បានជិះម៉ូតូមករកបុរសម្នាក់ជាអ្នកលក់អេតចាយ ក្នុងគោលបំណងទៅប្រាប់គាត់ឱ្យទៅមើលកូនស្រីឱ្យអ្នកគ្រូម្នាក់ ។ ពេលនោះ ខ្លួនក៏បានជួបនឹងឈ្មោះ [redacted] ស៊ីថាច ហើយគេក៏បបួលខ្លួនប្រើប្រាស់ថ្នាំញៀននៅចំណុចផ្ទះរបស់គេ ក្នុងភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប ពេលនោះខ្លួន និង ឈ្មោះ កែវ ស៊ីថាច ក៏បានប្រើប្រាស់ថ្នាំញៀនអស់ ០១ កញ្ចប់ ដែលថ្នាំញៀននោះជារបស់ឈ្មោះ[redacted]ស៊ីថាច ។ ពេលប្រើប្រាស់ថ្នាំញៀនរួច ខ្លួនក៏បានជិះម៉ូតូចេញពីផ្ទះរបស់[redacted]ស៊ីថាច ត្រឡប់មកកន្លែងចាក់ដីជិតផ្សារដំណាក់ចង្កើរវិញ ។ លុះដល់ម៉ោងជិត ៦ ល្ងាច ថ្ងៃខែឆ្នាំដដែល ខ្លួនបានជិះម៉ូតូត្រឡប់មកផ្ទះអ្នកលក់អេតចាយម្តងទៀត ក្នុងគោលបំណងយកមាន់មកផ្ញើទុក តែពេលដែលខ្លួនមកដល់ក៏ត្រូវបានសមត្ថកិច្ចចាប់ខ្លួនតែម្តង។

ខ្លួនទទួលស្គាល់ថាពិតជាបានទិញថ្នាំញៀនពីឈ្មោះ [redacted] ស៊ីថាច ជាច្រើនដងពិតមែន ដោយទិញក្នុងតម្លៃចន្លោះពី ២០០០០ (ពីរម៉ឺន) រៀល ទៅ ៣០០០០ (បីម៉ឺន) រៀល ហើយប្រើប្រាស់ជាមួយឈ្មោះ [redacted] ស៊ីថាច ។ ខ្លួនសូមបដិសេធថា ខ្លួនមិនដែលលក់ថ្នាំញៀននោះទេ ខ្លួនទើបតែស្គាល់ឈ្មោះ [redacted] ស៊ីថាច រយៈពេល ០១ ឆ្នាំ ប៉ុណ្ណោះ គឺស្គាល់ដោយសារតែខ្លួនបើកឡានដឹកដីនៅមុខសាលាខេត្តកែប និងបានស៊ីផឹកជាមួយគ្នា ហើយឈ្មោះ [redacted] ស៊ីថាច បានសួរខ្លួនថាចេះជក់ឬទេ ខ្លួនបានឆ្លើយថា ចេះ ចាប់តាំងពីពេលនោះមក ខ្លួន និងឈ្មោះ [redacted] ស៊ីថាច តែងតែប្រើប្រាស់ថ្នាំញៀនជាមួយគ្នាក្នុងមួយសប្តាហ៍ ប្រហែល ២ ឬ ៣ ដង ដោយថ្នាំញៀនទាំងនោះគឺខ្លួនទិញពីឈ្មោះ [redacted] ស៊ីថាច ។ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនតាំងពីឆ្នាំ ២០១៥ ដោយកាលនោះខ្លួនចេះប្រើប្រាស់ថ្នាំញៀនដោយសារតែខ្លួនបើកឡានដឹកទំនិញធុនធំនៅប៉ោយប៉ែត ហើយក្រោយមកខ្លួនក៏ឈប់ប្រើប្រាស់ ។ ថ្មីៗនេះ ដោយសារតែមានបញ្ហាក្នុងគ្រួសារ ទើបខ្លួនចាប់ផ្តើមជក់ថ្នាំញៀនឡើងវិញ ដោយខ្លួនបានទៅទិញថ្នាំញៀនពីឈ្មោះ [redacted] វ៉ាន់ចាន់សីហា ហៅ ខុច រស់នៅជិតផ្សារដំណាក់ចង្អើរចំនួន ០២ ដង ក្នុងម្តងៗទិញក្នុងតម្លៃ ៥០០០០ (ប្រាំម៉ឺន) រៀល។ ចំពោះឈ្មោះ [redacted] គុលា ខ្លួនមិនដែលស្គាល់ពីមុនមកទេ ទើបតែឃើញមុខនៅពេលដែលសមត្ថកិច្ចចាប់ខ្លួននេះតែម្តង ។ សមត្ថកិច្ចចាប់ខ្លួន បានដកហូតម៉ូតូ ០១ គ្រឿង ម៉ាកគុបជ្រុង ពណ៌ទឹកប៊ិច គ្មានផ្លាកលេខ និងទូរស័ព្ទ ០១ គ្រឿងម៉ាក Iphone 7។ សមត្ថកិច្ចបានឃាត់រូបខ្លួន ហើយបានធ្វើតេសពិនិត្យទឹកនោមលើរូបខ្លួន ជាលទ្ធផលគឺវិជ្ជមាន។

-ជនជាប់ចោទឈ្មោះ [redacted] **វ៉ាន់ចាន់សីហា** បានឆ្លើយថា: ខ្ញុំធ្លាប់ប្រើប្រាស់គ្រឿងញៀនតែមិនបានលក់ដូរទេ។ ខ្ញុំចេះប្រើប្រាស់ថ្នាំញៀនតាំងពីឆ្នាំ ២០១៧ មកម្ល៉េះ ខ្លួនមិនបានលក់ដូរគ្រឿងញៀនទេ។

-សាក្សីឈ្មោះ [redacted] **ប្រុស** នាយការិយាល័យប្រឆាំងបទល្មើសគ្រឿងញៀននៃកងរាជអាវុធហត្ថខេត្តកែប បានឆ្លើយបំភ្លឺថា៖ កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង ១៤ និង ៤០ នាទី ខ្លួនបានដឹកនាំកម្លាំងជំនាញ ដែលជាមន្ត្រីក្រោមឱវាទ ធ្វើការចុះបង្ក្រាបមុខសញ្ញាប្រើប្រាស់ និង ចែកចាយគ្រឿងញៀន ដោយខុសច្បាប់នៅចំណុចផ្ទះជួលមួយកន្លែង ស្ថិតក្នុងភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប ។ ក្នុងកិច្ចប្រតិបត្តិការនេះ កម្លាំងសមត្ថកិច្ចរបស់យើងបានឃាត់ខ្លួនជនល្មើសចំនួន ០៣ នាក់ ១/.ឈ្មោះ [redacted] ស៊ីថាច (ហៅ ខ្មាច) ភេទប្រុស អាយុ ៣៧ឆ្នាំ , ២/. ឈ្មោះ [redacted] គុលា ភេទប្រុស អាយុ ១៧ឆ្នាំ , ៣/. ឈ្មោះ [redacted] សុភ័ក្រ ភេទប្រុស អាយុ ៣៦ឆ្នាំ ដោយដកហូតបានរួមមាន ម្សៅក្រាមពណ៌សថ្លា ចំនួន ០៧ កញ្ចប់ មានទម្ងន់ ៣,៩៣ ក្រាម , ទូរស័ព្ទម៉ាក វីវ៉ូ ចំនួន ០១ គ្រឿង , ទូរស័ព្ទម៉ាក អិនបុចពិលចំនួន ០១ គ្រឿង , ដែកកេះ ចំនួន ០១ គ្រឿង , ដែកឆាប ចំនួន ០១ ដើម , ទុយយោ និង ដបទឹកសុទ្ធសម្រាប់ជក់ ចំនួន ០១ , ម៉ូតូម៉ាក ហុងដាគុបជ្រុង ពណ៌ទឹកប៊ិច គ្មានស្លាកលេខ ចំនួន ០១ គ្រឿង , ម៉ូតូមិនស្គាល់ម៉ាក ពណ៌ខ្មៅលាយក្រហម ពាក់ស្លាកលេខ ភ្នំពេញ 1A-7570 ចំនួន ០១ គ្រឿង និងម៉ូតូម៉ាក MSX ពណ៌ខ្មៅ គ្មានស្លាកលេខ ចំនួន ០១ គ្រឿង។ លុះនៅថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០២២ កម្លាំងការិយាល័យគ្រឿងញៀននៃកងរាជអាវុធហត្ថខេត្តកែប ក៏បានចាប់ខ្លួនឈ្មោះ [redacted] វ៉ាន់ចាន់សីហា ហៅ ខុច រួចបញ្ជូនមកតុលាការខេត្តកែបតែម្តង ។ តាមការស្រាវជ្រាវរបស់ការិយាល័យប្រឆាំងគ្រឿងញៀន ឈ្មោះ [redacted] ស៊ីថាច និង [redacted] វ៉ាន់ចាន់សីហា គឺជាមុខសញ្ញាជួញដូរថ្នាំញៀន ចំណែកឈ្មោះ [redacted] គុលា និង [redacted] សុភ័ក្រ គឺជាមុខសញ្ញាប្រើប្រាស់ថ្នាំញៀន មិនមែនជួញដូរថ្នាំញៀនទេ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា ៖ ឆ្លងតាមការសួរដេញដោលឃើញថាអំពើរបស់ឈ្មោះ [redacted] ស៊ីថាច និង [redacted] វ៉ាន់ចាន់សីហា គឺជាពាក់ព័ន្ធនឹងការជួញដូរគ្រឿងញៀន ចំណែកអំពើរបស់ឈ្មោះ [redacted] គុលា និង [redacted] សុភ័ក្រ តំណាងអយ្យការទុកសិទ្ធិជូនក្រុមប្រឹក្សាជំនុំជម្រះពិចារណាសម្រេច ។ តំណាងអយ្យការសូមរក្សាការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរ និងសូមអោយតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

-លោកមេធាវី ហែម សុខលីន មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ បានធ្វើសេចក្តីសន្និដ្ឋានការពារថា ៖ កូនក្តីរបស់ខ្លួនឈ្មោះ [redacted] សុភ័ក្រ បានឆ្លើយសារភាពគ្រប់តំណាក់កាលនៃនីតិវិធីថាបានប្រើប្រាស់ថ្នាំញៀនប្រាកដមែន តែមិនបានជួញដូរថ្នាំញៀននោះទេ។ ឆ្លងតាមការសួរដេញដោលនាពេលសវនាការ និងការបញ្ជាក់របស់លោកប្រធានការិយាល័យប្រឆាំងគ្រឿងញៀននៃកងរាជអាវុធហត្ថខេត្តកែប ក៏បានបង្ហាញថាកូនក្តីខ្លួនជាមុខសញ្ញាប្រើប្រាស់

ថ្នាំញៀនដែរ។ ដូចនេះ ក្នុងនាខ្លួនជាមេធាវីការពារសិទ្ធិអោយជនជាប់ចោទ [redacted] សុភ័ក្រ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះមេត្តាសម្រេចប្តូរបទចោទប្រកាន់លើកូនក្តីខ្លួនពីបទជួញដូរ មកជាបទប្រើប្រាស់ថ្នាំញៀនវិញ។

-លោកមេធាវី [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] តុលា បានធ្វើសេចក្តីសន្និដ្ឋានការពារថា

កូនក្តីរបស់ខ្លួនឈ្មោះ [redacted] តុលា មិនបានជួញដូរថ្នាំញៀនទេ គឺឈ្មោះ [redacted] ស៊ីថាច ទូរស័ព្ទហៅកូនក្តីខ្លួនអោយមកជាប់ជាមួយ។ កូនក្តីរបស់ខ្លួនមិនមានឆន្ទៈក្នុងការលក់ដូរថ្នាំញៀនទេ គឺគ្រាន់តែជក់ប៉ុណ្ណោះ។ ដូចនេះ ក្នុងនាមមេធាវីការពារសិទ្ធិអោយជនជាប់ចោទ [redacted] តុលា ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះមេត្តាប្តូរបទចោទប្រកាន់លើកូនក្តីខ្លួនពីបទជួញដូរ មកជាប្រើប្រាស់ថ្នាំញៀនវិញ។ កូនក្តីខ្លួនជាអនីតិជនអាយុ ១៧ឆ្នាំ ស្នើសុំតុលាការមេត្តាផ្តល់ស្ថានសម្រាលទោសដល់កូនក្តីខ្លួនផង។

-ជនជាប់ចោទឈ្មោះ [redacted] **ស៊ីថាច , [redacted] តុលា , [redacted] សុភ័ក្រ , [redacted] វ៉ាន់ចាន់សីហា** ហៅ ឌូច បាននិយាយសម្តីចុងក្រោយប្រហាក់ប្រហែលគ្នាថា ៖ សូមឲ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសលើរូបខ្លួនផង។

ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការ
ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារពាក់ព័ន្ធនឹងសំណុំរឿង
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ
ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ
ក្រោយពីបានពិនិត្យ ពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការយល់ឃើញថា

1. តុលាការបានទទួលបណ្តឹងតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរលេខ ១៤ ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០២២ ដែលបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ស៊ីថាច, [redacted] តុលា, [redacted] សុភ័ក្រ និង [redacted] វ៉ាន់ចាន់សីហា ហៅ ឌូច មកជំនុំជម្រះ មានលក្ខណៈត្រឹមត្រូវតាមបញ្ញត្តិមាត្រា ២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបានបង្ហាញពីសមត្ថកិច្ចតុលាការព្រហ្មទណ្ឌនៃសាលាដំបូងខេត្តកែប ក្នុងការជំនុំជម្រះរឿងក្តីនេះ។

2. ជនជាប់ចោទឈ្មោះ [redacted] តុលា កើតថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៥ គិតត្រឹមថ្ងៃប្រព្រឹត្តបទល្មើសថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០២២ មានអាយុ ១៦ ឆ្នាំ ៣ខែ ២២ថ្ងៃ ជាអនីតិជន ត្រូវបានចោទប្រកាន់ពីបទមជ្ឈិម ដូចនេះតុលាការប្រកាសបើកសវនាការជាអសាធារណៈ និងជំនុំជម្រះដោយក្រុមប្រឹក្សា តាមបញ្ញត្តិមាត្រា ៤៤ និងមាត្រា ៤៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន។

3. ជនជាប់ចោទឈ្មោះ [redacted] ស៊ីថាច បានឆ្លើយសារភាពថា ពួកខ្លួនពិតជាបានទិញថ្នាំញៀនដើម្បីយកមកប្រើប្រាស់ និងលក់ដូរបន្ត ពិតប្រាកដមែន ។ ចម្លើយសារភាពនេះមានលក្ខណៈស៊ីសង្វាក់ទៅនឹងចម្លើយរបស់ជនជាប់ចោទ [redacted] សុភ័ក្រ, [redacted] តុលា, របាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងភស្តុតាងនានាក្នុងសំណុំរឿង អាចអោយតុលាការលើកយកចម្លើយសារភាពនេះមកពិចារណាបាន។

4. ជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ចាន់សីហា ហៅ ឌូច បានឆ្លើយថា ខ្លួនមិនបានលក់ថ្នាំញៀនទេ គឺគ្រាន់តែប្រើប្រាស់។ ចម្លើយនេះតុលាការយល់ឃើញថា គឺគ្រាន់តែជាការឆ្លើយដោះសារដើម្បីអោយរួចផុតពីការទទួលខុសត្រូវ ដោយហេតុថា ឈ្មោះ [redacted] តុលា បានសារភាពថា ខ្លួនទិញថ្នាំញៀនពីឈ្មោះ ម៉ាប់ ដែលជាកូនចៅរបស់ [redacted] វ៉ាន់ចាន់សីហា នៅផ្ទះរបស់ [redacted] វ៉ាន់ចាន់សីហា តែម្តង។ បន្ថែមពីនេះ តាមការបំភ្លឺរបស់លោក [illegible] ប្រធានការិយាល័យគ្រឿងញៀននៃកងរាជអាវុធហត្ថខេត្តកែបបានបញ្ជាក់ថា តាមការស្រាវជ្រាវ ឈ្មោះ [redacted] វ៉ាន់ចាន់សីហា គឺជាមុខសញ្ញាជួញដូរថ្នាំញៀន។

5. ជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ បានឆ្លើយសារភាពថាខ្លួនពិតជាបានទិញថ្នាំញៀនមកប្រើប្រាស់ប្រាកដមែន តែខ្លួនមិនដែលលក់ដូរថ្នាំញៀនទៅអោយអ្នកណាទេ គឺទិញយកមកជក់តែប៉ុណ្ណោះ ចម្លើយសារភាពនេះមានភាពស៊ីសង្វាក់ទៅនឹងភស្តុតាងដូចខាងក្រោម៖

-របាយការណ៍សរុបលេខ ០៦១/០២២ របស់មេបញ្ជាការរងកងរាជអាវុធហត្ថខេត្តកែបដែលបានសន្និដ្ឋានថា តាមការស្រាវជ្រាវ ស៊ើបអង្កេតបានអោយដឹងថា ឈ្មោះ [redacted] សុភ័ក្រ ជាអ្នកប្រើប្រាស់គ្រឿងញៀន។

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីថាច ដែលឆ្លើយសារភាពថា ឈ្មោះ [redacted] សុភ័ក្រ ទិញថ្នាំញៀនពីខ្លួនម្តង ២០០០០(ពីរម៉ឺន)រៀលយកទៅជក់។

-ចម្លើយបំភ្លឺនាពេលសវនាការរបស់លោក [redacted] ប្រុស ប្រធានការិយាល័យប្រឆាំងបទល្មើសគ្រឿងញៀននៃកងរាជអាវុធហត្ថខេត្តកែបបានបញ្ជាក់ថា តាមការស្រាវជ្រាវ ឈ្មោះ [redacted] សុភ័ក្រ គឺជាមុខសញ្ញាប្រើប្រាស់ថ្នាំញៀន មិនមែនជួញដូរថ្នាំញៀនទេ។

6. ជនជាប់ចោទឈ្មោះ [redacted] តុលា បានឆ្លើយសារភាពថាខ្លួនពិតជាបានទិញថ្នាំញៀនមកប្រើប្រាស់ប្រាកដមែន តែខ្លួនមិនដែលលក់ដូរថ្នាំញៀនទៅអោយអ្នកណាទេ ចម្លើយសារភាពនេះមានភាពស៊ីសង្វាក់ទៅនឹងភស្តុតាងដូចខាងក្រោម៖

-របាយការណ៍សរុបលេខ ០៦១/០២២ របស់មេបញ្ជាការរងកងរាជអាវុធហត្ថខេត្តកែបដែលបានសន្និដ្ឋានថា តាមការស្រាវជ្រាវ ស៊ើបអង្កេតបានអោយដឹងថា ឈ្មោះ [redacted] តុលា ជាអ្នកប្រើប្រាស់គ្រឿងញៀន។

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីថាច ដែលឆ្លើយសារភាពថា ពេលសមត្ថកិច្ចចាប់ឃាត់ខ្លួនហើយបានអោយខ្លួនទូរស័ព្ទទៅ [redacted] តុលា ពីងអោយជួយទិញថ្នាំញៀនអោយខ្លួន ៦០០០០រៀល ពេល [redacted] តុលា យកថ្នាំញៀនមកអោយក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។

-ចម្លើយបំភ្លឺនាពេលសវនាការរបស់លោក [redacted] ប្រុស ប្រធានការិយាល័យប្រឆាំងបទល្មើសគ្រឿងញៀននៃកងរាជអាវុធហត្ថខេត្តកែបបានបញ្ជាក់ថា តាមការស្រាវជ្រាវ ឈ្មោះ [redacted] តុលា គឺជាមុខសញ្ញាប្រើប្រាស់ថ្នាំញៀន មិនមែនជួញដូរថ្នាំញៀនទេ។

7. តាមកំណត់ហេតុធ្វើតេស្តពិសោធន៍រកសារធាតុញៀនក្នុងខ្លួនរបស់កងរាជអាវុធហត្ថខេត្តកែប ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២ បានបង្ហាញថា ឈ្មោះ [redacted] ស៊ីថាច ឈ្មោះ [redacted] តុលា និង ឈ្មោះ [redacted] សុភ័ក្រ មានផ្ទុកសារធាតុញៀន។

8. អំពើប្រព្រឹត្តរបស់ឈ្មោះ [redacted] ស៊ីថាច ដែលបានទិញថ្នាំញៀនយកមកជក់និងលក់បន្តទៅអោយអ្នកដទៃ គឺមានធាតុផ្សំគ្រប់គ្រាន់ជាបទជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសព្រហ្មទណ្ឌដែលមានចែង និងអោយផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

9. អំពើប្រព្រឹត្តរបស់ឈ្មោះ [redacted] ាន់ចាន់សីហា ហៅ ខូច ដែលបានទិញថ្នាំញៀនយកមកលក់បន្តទៅអោយអ្នកដទៃ គឺមានធាតុផ្សំគ្រប់គ្រាន់ជាបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសព្រហ្មទណ្ឌដែលមានចែង និងអោយផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

10.អំពើប្រព្រឹត្តរបស់ឈ្មោះ [redacted] សុភ័ក្រ និង [redacted] តុលា ដែលបានទិញថ្នាំញៀនយកមកសំរាប់ជក់ គឺមានធាតុផ្សំគ្រប់គ្រាន់ជាបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសព្រហ្មទណ្ឌដែលមានចែង និងអោយផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ អំពើប្រព្រឹត្តរបស់ឈ្មោះ [redacted] សុភ័ក្រ និង [redacted] តុលា មិនមានធាតុផ្សំគ្រប់គ្រាន់ជាបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀននោះទេ ដូចនេះ តុលាការគប្បីអោយឈ្មោះ [redacted] សុភ័ក្រ និង [redacted] តុលា រួចផុតពីបទចោទប្រកាន់ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។

11.តុលាការគប្បីសម្រេចរឹបអូស តាមមាត្រា ៨៤ និងមាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀននូវវត្ថុតាង រួមមាន៖

-ថ្នាំញៀនប្រភេទម្សៅក្រាមពណ៌សថ្លា ចំនួន ០៧ កញ្ចប់ មានទម្ងន់ ៣,៩៣ ក្រាម

- ទូរស័ព្ទដៃចំនួន ០២ គ្រឿង (ម៉ាក vivo ០១ គ្រឿង និង ចុចពិល ០១ គ្រឿង)

- ដែកកេះ ចំនួន ០១

- ដែកឆាប ចំនួន ០១

- ទុយយោ និង ដបទឹកសម្រាប់ជក់ចំនួន ០១

- ម៉ូតូចំនួន ០៣ គ្រឿង ( ១.ម៉ាកហុងដា គុបជ្រុង ពណ៌ទឹកប៊ិច គ្មានស្លាកលេខ ០១ គ្រឿង, ២.ម៉ូតូមិនស្គាល់ម៉ាក ពណ៌ខ្មៅលាយក្រហម ពាក់ស្លាកលេខ 1Aភ្នំពេញ 7570 ០១ គ្រឿង ៣.ម៉ូតូម៉ាក MSX ពណ៌ខ្មៅ គ្មានស្លាកលេខ ចំនួន ០១ គ្រឿង) ។

## ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី

១.ផ្តន្ទាទោស ៖

១.១ ឈ្មោះ កែវ ស៊ីថាច ដាក់ពន្ធនាគារកំណត់ចំនួន ០២ (ពីរ)ឆ្នាំ ពីបទជួញដូរ និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២។

១.២ ឈ្មោះ [redacted] វ៉ាន់ចាន់សីហា ហៅ ខួច ដាក់ពន្ធនាគារកំណត់ចំនួន ០២ (ពីរ)ឆ្នាំ ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២។

១.៣ ឈ្មោះ [redacted] តុលា ដាក់ពន្ធនាគារកំណត់ចំនួន ០៦ (ប្រាំមួយ)ខែ ពីបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២។

១.៤ ឈ្មោះ មាំ សុភ័ក្រ្ត ដាក់ពន្ធនាគារកំណត់ចំនួន ៦ (ប្រាំមួយ)ខែ ពីបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿនញៀន ប្រព្រឹត្តនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២។

២.អោយឈ្មោះ [redacted]សុភ័ក្រ្ត និងឈ្មោះ [redacted] តុលា រួចផុតពីបទចោទប្រកាន់ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២ តាមមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣. រឹបអូសតាមមាត្រា ៨៤ និងមាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នូវវត្ថុតាងដូចខាងក្រោម៖

- ថ្នាំញៀនប្រភេទម្សៅក្រាមពណ៌សថ្លា ចំនួន ០៧ កញ្ចប់ មានទម្ងន់ ៣,៩៣ ក្រាម

- ទូរស័ព្ទដៃចំនួន ០២ គ្រឿង (ម៉ាក vivo ០១ គ្រឿង និង ចុចពិល ០១ គ្រឿង)

- ដែកកេះ ចំនួន ០១

- ដែកឆាប ចំនួន ០១

- ទុយយោ និង ដបទឹកសម្រាប់ជក់ចំនួន ០១

- ម៉ូតូចំនួន ០៣គ្រឿង (១.ម៉ាកហុងដាគុបជ្រុង ពណ៌ទឹកប៊ិច គ្មានស្លាកលេខ ០១ គ្រឿង ២.ម៉ូតូមិនស្គាល់ម៉ាក ពណ៌ខ្មៅលាយក្រហម ពាក់ស្លាកលេខភ្នំពេញ 1A-7570 មួយគ្រឿង ៣.ម៉ូតូម៉ាក MSX ពណ៌ខ្មៅ គ្មានស្លាកលេខ ចំនួន ០១ គ្រឿង) ។

៤.សាលក្រមនេះ ជំនុំជម្រះជាអសាធារណៈចំពោះមុខជនជាប់ចោទ និង ប្រកាសនៅថ្ងៃទី០៣ ខែសីហា ឆ្នាំ ២០២២។

**ចៅ ក្រម ប្រឹ ក្សា**

ហត្ថលេខា និងត្រា៖ [redacted]

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ហត្ថលេខា និងត្រា ៖ [redacted]

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា៖ [redacted]

---

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ៦កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

កែប, ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០២២

**ក្រឡាបញ្ជីសវនាការ**

[redacted]